# ១

## គុណព្រះពុទ្ធ

ពាក្យថា ព្រះពុទ្ធ មិនមែនជាឈ្មោះទេ តែជាបរមងារ ដែលមានន័យថា **អ្នកត្រាស់ដឹង** ។ ព្រះនាមព្រះអង្គ គឺ **គោតម** ព្រះអង្គជាព្រះរាជបុត្រនៃព្រះបាទ សុទ្ធោទន៍ និង ព្រះនាង សិរិមហាមាយា ។

ក្នុងព្រះជន្ម ១៦ព្រះវស្សា ទ្រង់បានអភិសេកជាមួយនឹង ព្រះអង្គម្ចាស់ក្សត្រី យសោធរា។ ព្រះអង្គគង់នៅក្នុងវាំងដោយ សុខសប្បាយពុំដែលស្គាល់អ្វីដែលហៅថាទុក្ខនោះទេ ។ តែមានពេលមួយ ព្រះអង្គបានយាងកំសាន្តនៅខាងក្រៅព្រះរាជវាំង ក៏បានជួបនូវហេតុការណ៍ដ៏សង្វេគខ្លះ ដែលធ្វើឲ្យព្រះអង្គពិចារណាទៅលើ សេចក្តីទុក្ខទាំងពួង នៃមនុស្សលោកយើងនេះ និងធ្វើឲ្យព្រះអង្គចង់រកផ្លូវដោះស្រាយ ។

ក្នុងព្រះជន្ម ២៩ព្រះវស្សា បន្ទាប់ពីព្រះមហេសី បានប្រសូតព្រះរាជបុត្រជាលើកដំបូង ព្រះនាម រាហុល មក នៅវេលាយប់ ព្រះអង្គ និងនាយឆន្នអាមាត្យ បានចាកចេញពីព្រះរាជវាំង ដោយគ្មានអ្នកណាម្នាក់ដឹង។ ក្នុងការស្វែងរកចម្លើយខាងលើនេះ ព្រះអង្គបានជួបនឹងគ្រូខ្លះដែរ តែធម៌របស់គ្រូទាំងនោះ ពុំអាចដោះស្រាយចំណោទ របស់ព្រះអង្គបានឡើយ។ ចំណោទ គឺ « ដោយឃើញថា ជីវិតជាទុក្ខ តើត្រូវធ្វើដូចម្តេចដើម្បី រំលត់ទុក្ខ »។

ធម៌ដែលព្រះអង្គត្រាស់ដឹង ដើម្បីដោះស្រាយនូវចំណោទនោះ គឺ **អរិយសច្ចៈ ៤** ដែលមាន៖

**១-ទុក្ខ អរិយសច្ច** : ទុក្ខ ជារបស់ពិតដ៏ប្រសើរ

**២-ទុក្ខសមុទយ អរិយសច្ច** : ហេតុឲ្យកើតទុក្ខ ជារបស់ពិតដ៏ប្រសើរ

**៣- ទុក្ខនិរោធ អរិយសច្ច** : ការរលត់ទុក្ខ ជារបស់ពិតដ៏ប្រសើរ

**៤-ទុក្ខនិរោធគាមិនីបដិបទា អរិយសច្ច** : ផ្លូវបដិបត្តិឲ្យដល់នូវការរំលត់ទុក្ខ ជារបស់ពិតដ៏ប្រសើរ ។

ខ្ញុំ រំលឹក ពុទ្ធប្រវត្តិខ្លះតែប៉ុណ្ណោះ ដើម្បីជូនលោកអ្នកគ្រាន់នឹងពិចារណានូវ មនសិការ និង ការតស៊ូ យ៉ាងស្វិតស្វាញ របស់ព្រះពុទ្ធដើម្បីជួយសត្វលោកឲ្យរួចផុតចាកទុក្ខ ក៏ដូចជួយយើងឲ្យបានសេចក្ដីសុខដែរ ។ ពីព្រោះទុក្ខ និង សុខ បដិបក្ខ (ប្រឆាំង) នឹងគ្នា ៖ បើមួយមាន មួយទៀតត្រូវតែគ្មាន គឺថា របស់ទាំងពីរហ្នឹង មិនអាចកើតឡើងជាមួយគ្នានៅពេលតែមួយបានទេ ។ ឧបមាដូចជា (សោមនស្ស និង ទោមនស្ស) ( បញ្ញា និង អវិជ្ជា ) (កុសល និង អកុសល) ជាដើម ។ ចំពោះអ្នកដែលសង្ស័យ ថាតើព្រះពុទ្ធមានមែន ឬមិនមាន ។ តើព្រះពុទ្ធត្រាស់ដឹងពិតមែន ឬមិនពិត ខ្ញុំសូមជូនចម្លើយ គ្រាន់នឹងយកទៅពិចារណា ដូចតទៅ ៖

១- ព្រះពុទ្ធសាសនា កើតក្រោយ សាសនាជាច្រើន ដូចជាព្រហ្មញ្ញសាសនា ជាដើម ពីព្រោះបន្ទាប់ពីចេញពីព្រះរាជវាំង ព្រះអង្គបានជួបគ្រូជាតាបសខ្លះដែរ មុននឹងព្រះអង្គស្វែងរកមោក្ខធម៌(ធម៌រួចផុត)ដោយពឹងតែទៅលើព្រះអង្គឯង ។

២- ធម៌ ក្នុងព្រះពុទ្ធសាសនា មានស្ដីពី ព្រះនិព្វាន ដែលមានន័យខុសពីនិព្វានរបស់សាសនាឯទៀតនៃសម័យនោះ ។ ដូច្នេះនិយមន័យថ្មីរបស់ពាក្យ **និព្វាន** តាមព្រះពុទ្ធសាសនា ព្រមទាំងផ្លូវបដិបត្តិដើម្បីបានសម្រេចនិព្វាន តើចេញមកពីណា ? អ្នកណាជាអ្នកបង្កើត ?

៣- ប្រសិនបើជាមិនមែនជានិយមន័យតាមព្រះពុទ្ធសាសនា ហើយជានិយមន័យរបស់សាសនាដទៃដែលមាននៅពេលនោះ ម្ដេចក៏អ្នកបួសក្នុងសាសនាដទៃនោះមិនតវ៉ា នៅពេលដែលព្រះអង្គប្រើពាក្យ និព្វាន ព្រមទាំងផ្លូវនាំទៅនិព្វាន គឺ អរិយសច្ចៈ ៤ ?

៤- ប្រសិនបើជាឆ្លើយនូវសំណួរខាងលើនេះមិនរួចទេ  នោះយើងអាចសន្និដ្ឋាន ថា ៖ ពាក្យនិព្វានក្នុងព្រះពុទ្ធសាសនា ព្រមទាំង **អរិយសច្ចៈ ៤** គឺចេញមកពីព្រះពុទ្ធពិត ។ បើព្រះពុទ្ធ រកឃើញ អរិយសច្ចៈ ៤ បានន័យថា អ្នកដែលបង្កើត អរិយសច្ចៈ ៤ ពិតជាកើតនៅស្ថានមនុស្សលោកយើងនេះ កាលពីជាង ២៥០០ឆ្នាំមុន ។

មនសិការរបស់ព្រះអង្គដើម្បីជួយសត្វលោក មិនមែនទើបតែជាតិចុងក្រោយនេះទេ ប្រសិនបើជាព្រះអង្គចង់សម្រេចព្រះនិព្វាននោះព្រះអង្គអាចសម្រេចអរហត្តផលបាន តាំងពីកាលសម័យ ព្រះពុទ្ធព្រះនាម **ទីបង្ករ** ម៉្លេះ។  តែដោយព្រះអង្គចង់ប្រោសសត្វលោកនេះហើយ បានជាកាលសម័យព្រះពុទ្ធ **ទីបង្ករ** ព្រះអង្គមានកំណើតជាព្រាហ្មណ៍នាម **សុមេធបណ្ឌិត** បានខំកសាងបារមីចំនួន បួនអសង្ខេយ្យនិងមួយសែនកប្បថែមទៀត ដើម្បីនឹងបានត្រាស់ជាព្រះពុទ្ធនៃយើងសព្វថ្ងៃនេះ ។ មកដល់ត្រង់នេះយើងឃើញថា សូម្បីតែ សាសនាព្រះពុទ្ធក៏មិនទៀងដែរ ថ្វីបើធម៌របស់ព្រះពុទ្ធជាសច្ចធម៌ មិនផ្លាស់ប្តូរទៅតាមកាលក៏ដោយ។ ពីព្រោះថា បើសាសនាព្រះពុទ្ធ **ទីបង្ករ**ទៀងនោះ  ធម៌ដែលព្រះអង្គបានត្រាស់ដឹងនោះ ក៏នឹងនៅរហូតដល់ព្រះពុទ្ធ **គោតម** យើងទៅហើយ ។ តែព្រោះតែធម៌នោះវិនាសសាបសូន្យហើយបានជាព្រះពុទ្ធយើងទ្រង់ខំរក ធ្វើទុក្ករកិរិយាទំរាំបានត្រាស់ដឹង។  យើងសួរថា ហេតុអ្វីបានជាត្រូវដឹងគុណព្រះ ? ពីព្រោះព្រះអង្គ ទ្រង់ធ្វើពលិកម្មគ្រប់បែបយ៉ាងនេះ គឺដើម្បីខ្លួនព្រះអង្គទេតើ ?  ការសួរយ៉ាងនេះមិនខុសទេ បើយើងប្រដូចមកខ្លួនយើងម្នាក់ៗ ដែលខំរៀនសូត្រ ដោយធ្វើពលិកម្មគ្រប់បែបយ៉ាង ព្រោះដើម្បីថ្ងៃមុខមានអនាគតល្អ ។  តែចំពោះព្រះពុទ្ធ  មានចេតនា ខុសពីយើងតាំងពីដើមមក ដូចខ្ញុំបានជំរាបខាងលើរួចមកហើយ ថាព្រះអង្គ អាចសម្រេចនិព្វានបាន តាំងពីព្រះពុទ្ធទីបង្ករ ម៉្លេះ។ តែយើងអាចសួរថា តើមានអ្វីជាភស្តុតាង។ ឆ្លើយថា ភស្តុតាងគឺនៅពេលដែលព្រះអង្គសម្រេចព្រះទ័យចេញចាកពីវាំង សព្វព្រះទ័យប្តូរ ការរស់នៅ

ដោយសុខសប្បាយជួបជុំគ្រួសារនិងបុត្រដែលទើបនឹងប្រសូត មករស់នៅក្នុងព្រៃវិញ ហាលភ្លៀងហាលខ្យល់។ លុះព្រះអង្គបានត្រាស់ដឹងហើយ **មារ**ចិត្តបាប បាននិមន្តព្រះអង្គឲ្យចូលនិព្វាន តែព្រះអង្គមិនព្រមចូល ពីព្រោះព្រះអង្គចង់នៅប្រោសសត្វលោកដោយយកធម៌ព្រះអង្គទៅទូន្មាន ចំនួន៤៥ វស្សា ទាំងថ្ងៃទាំងយប់ ទុកពេលសម្រាកតែបន្តិចបន្តួច ។ បើព្រះអង្គ ចង់បានសុខតែត្រឹមព្រះអង្គឯង ឬ ត្រឹមតែគ្រួសារព្រះរាជវង្សព្រះអង្គ នោះព្រះអង្គ មិនខំនិមន្តទៅពន្យល់រហូតដល់ដង្ហើមចុងក្រោយនោះទេ ។ ការដឹងគុណព្រះអង្គ បានប្រយោជន៍មកយើង មិនមែនបានប្រយោជន៍ ដល់ព្រះអង្គ ឬ ដល់ញាតិវង្សព្រះអង្គឡើយ ពីព្រោះព្រះអង្គ ព្រមទាំងញាតិវង្សខ្លះ បានសម្រេចនិព្វានរួចទៅហើយ អស់ត្រូវការគុណបំណាច់ ឬ កិត្តិយស អ្វីទៀតឡើយ។

ពាក្យថាដឹងគុណព្រះពុទ្ធ គឺ ទទួលស្គាល់ គុណធម៌របស់ព្រះអង្គកាលព្រះអង្គគង់នៅលើលោកយើងនេះនៅឡើយ បើនិយាយអំពីគុណសម្បត្តិព្រះអង្គ ដូចជាព្រះអង្គជាព្រះអរហន្ត ឆ្ងាយចាកកិលេស គឺគ្រឿងសៅហ្មង តាំងពីកិលេសគ្រោតគ្រាត រហូតដល់កិលេសដែលល្អិតសុខុមដេកត្រាំក្នុងសន្តាន បីដូចជាធូលីដែលតោងលើស្បែក ហើយក៏ក្លាយទៅជាក្អែល ទាល់តែងូតទឹកដុះលាងស្បែក ទើបអស់ធូលីនោះ ។

បើនិយាយពីគុណបំណាច់វិញ ដូចជាព្រះអង្គចែកធម៌ព្រះអង្គ ទុកដូចជាកេរមរតកមកឲ្យយើងរហូតដល់សព្វថ្ងៃនេះ ។ ពីព្រោះធម៌ព្រះអង្គ បង្ហាញផ្លូវដែលយើងគប្បីដើរដើម្បីបានសេចក្ដីសុខ។ កេរមរតកនេះមានតម្លៃ ជាង លុយកាក់មាសប្រាក់ផ្ទះសំបែងដែលឪពុកម្ដាយចែកឲ្យយើងទៅទៀត ពីព្រោះយើងចំណាយប្រាក់កាសសព្វថ្ងៃ ក៏ដើម្បីបានសេចក្ដីសុខដែរ ។

ខ្ញុំបានអានសៀវភៅអប់រំ ជាភាសាបរទេសខ្លះ គេសរសេរថាបើយើងស្រឡាញ់ ឬ ចង់បានកាយវិការ សំដីសំដៅ ចរិយា ឬចិត្តគំនិតដូចអ្នកណាមួយ នោះគេឲ្យយើងយកអ្នក

*នោះធ្វើជាគំរូ យើងថតទុកក្នុងចិត្តយើង នូវចិត្តគំនិតពាក្យសំដីកាយវិការរបស់អ្នកនោះ។ យើងធ្លាប់ឃើញហើយ មានអ្នកខ្លះដោយស្រឡាញ់អ្នកចម្រៀងល្បីៗណាមួយ ក៏ខំស្លៀកពាក់ខោអាវ ធ្វើឫកពា ធ្វើសម្លេងច្រៀងឲ្យដូចអ្នកចម្រៀងនោះ។ ចុះបើយើងឃើញថា ព្រះពុទ្ធ ព្រះអង្គមានគុណធម៌ដែលយើងចង់បាន នោះយើងយកព្រះអង្គជាគ្រូ ជាគំរូនៃយើង ហើយនៅពេលមានបញ្ហាណាមួយចោទឡើង យើងនឹកទៅគុណធម៌នោះៗ ។ ឧបមា មាន បញ្ហា ឬ ការចោទសួរម្តងៗ យើងនឹកថា បើព្រះពុទ្ធ ព្រះអង្គនឹងដោះស្រាយតាមរបៀបនេះ ។ នេះហើយដែលថា យើងនឹកគុណព្រះពុទ្ធ ដោយយើងលើកព្រះអង្គជាគំរូ ។ ដោយធម៌ព្រះ នាំយើងទៅរកសេចក្តីសុខ ដូច្នេះការបដិបត្តិធម៌ព្រះ ឬ ការនឹកគុណព្រះនឹងនាំយើងទៅរកសេចក្តីសុខ។ តែត្រូវប្រយ័ត្នដែរ ថ្វីបើធម៌ព្រះមានតែមួយ ការបកស្រាយអាចមានច្រើន ហើយមិនដូចគ្នា[1] ក៏មាន ។ មនុស្សយើងគ្រប់រូប ទាំងយើងទាំងគេ សុទ្ធតែចង់បាន សេចក្តីសុខ ។ សូម្បីតែសត្វតិរច្ឆាន ក៏វាចង់បានសេចក្តីសុខដែរ ! ហើយភ័យខ្លាច កាលណាវាឃើញទុក្ខ ឃើញសេចក្តីស្លាប់ជិតមកដល់ ។ ដូច្នេះ បើយើងយកវាជាអាហារ មុននឹងសម្លាប់ កុំធ្វើបាបវាពេក រហូតដល់យកវាទៅស្ងោរទាំងរស់ ដូចជាការស្ងោរអណ្តើក ឬ ស្ងោរបង្កងទាំងរស់ជាដើម ។*

[1] *សូមមើល កាលាមក្សត្រិយ៍ នៅក្នុង បិដកលេខ៤១ ទំព័រ ២១៦ មានទៅ* site internet
www.btkhmer.com *ផ្នែក* **ជាតាសាខ្មែរ ។**